AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

# សិលាចារឹកគោកអង្គាញ់ K.៨៤៤

## ១- ព័ត៌មានទូទៅ

បុរាណដ្ឋានគោកអង្គាញ់ ស្ថិតនៅក្នុងឃុំក្តីរុន ស្រុកពួក ខេត្តសៀមរាបស្ថិតនៅទិសអាគ្នេយ៍ត្រពាំងជូនមាសប្រមាណជា១,៥គីឡូម៉ែត្រ និងខាងកើតភូមិព្រៃយាង១គីឡូម៉ែត្រ។[១] នៅក្នុងឯកសាររបស់លោក ហ្សក សេដែស ហៅឈ្មោះទីនេះថា គុកអង្គាញ់ (Kŭk Aṅkăṅ)។[២] នៅទីនោះមានប៉មប្រាសាទមួយធ្វើអំពីឥដ្ឋ ព័ទ្ធជុំវិញដោយគូទឹក មានផ្លូវចូលពីទិសខាងកើត។[៣] មេទ្វារមានសិលាចារឹកចារចំនួន៤០បន្ទាត់នេះ បានរកឃើញនៅខែធ្នូ ឆ្នាំ១៩៣៥ ដោយអ្នកផ្តិតសិលាចារឹកនៃមន្ទីរអភិរក្សអង្គរ និងបានយកមករក្សាទុកដោយចុះបញ្ជីសារពើភណ្ឌលេខ៣៧៧០។

សិលាចារឹកនេះ បាក់ជាពីរបំណាក់។ នៅផ្នែកខាងស្តាំ នៃបំណាក់ខាងលើ ផ្ទៃថ្មបែក នាំឱ្យបានអក្សរបន្តិចបន្តួច ដែលអាចយល់បាននូវពាក្យដែលបាត់មួយចំនួន។ នៅបន្ទាត់ទី៤ មានផ្ទៃថ្មខូចខាត បាត់អក្សរ៤-៥តួ ពុំអាចយល់បានថាបាត់ពាក្យអ្វីខ្លះ។ បំណាក់ផ្នែកខាងក្រោម ផ្ទៃថ្មខាងស្តាំបានបែក ប៉ុន្តែយើងក៏អាចយល់បាននូវពាក្យដែលបាត់នោះបានផងដែរ។ អត្ថបទនេះពុំមានកាលបរិច្ឆេទទេ ប៉ុន្តែបើផ្អែកតាមរូបរាងអក្សរ «រ» ដែលដូចទៅនឹងអក្សរ «ប» តែមានប្រឡោះកណ្តាលចង្អៀត លោក សេដែស បានកំណត់ថាសិលាចារឹកនេះមានអាយុកាលមិនហួសស.វ.ទី១០ឡើយ ព្រោះទម្រង់អក្សរ «រ» របៀបនេះលែងឃើញប្រើក្រោយពីពេលនោះទេ។ ចំណែកឯលោក ចេណ្ណីរ វិញ បានកំណត់អាយុកាលសិលាចារឹកនេះនៅចន្លោះពីស.វ.ទី៩-១១ គឺរវាងគ.ស.៨៧៨-១០៧៧។

លោក ហ្សក សេដែស បានសិក្សាសិលាចារឹកនេះ ចុះផ្សាយនៅក្នុងសៀវភៅរបស់លោក ដែលមានចំណងជើងថា «សិលាចារឹកនៃប្រទេសកម្ពុជា» ក្បាលទី៥ នៅឆ្នាំ១៩៥៣

[១] https://cisark.mcfa.gov.kh/core/showsite.php?id=4844

[២] សេដែស, ១៩៥៣។

[៣] https://cisark.mcfa.gov.kh/core/showsite.php?id=4844

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ជាភាសាបារាំង។ ក្រោយមក លោក ហ្វីលីព ចេណ្ណឹរ បានសិក្សាសិលាចារឹកនេះជាភាសាអង់គ្លេសនៅក្នុងស្នាដៃ Part xml, № 44 និងចុះផ្សាយនៅគេហទំព័រ http://sealang.net/ok/corpus.htm។[៤]

ចំពោះអត្ថន័យសំខាន់នៃសិលាចារឹកនេះ គឺជាការបង្ហាញអំពីតង្វាយជាដីនិងគោគផលសម្រាប់បូជាដល់ប្រាសាទសិវលិង្គពីរកន្ទែង ហើយប្រាសាទនោះគឺជាបុណ្យកសាងឡើងដោយព្រាហ្មណ៍ជាអ្នកបួសដែលពុំបានបង្ហាញឈ្មោះ។ សេចក្តីមួយភាគធំក្នុងអត្ថបទនេះគឺជាការរៀបរាប់អំពីព្រំប្រទល់ដីដែលថ្វាយទៅកាន់ប្រាសាទសិវលិង្គទាំងពីរ។ ចុងបញ្ចប់នៃអត្ថបទ បានបញ្ជាក់ថាដីទាំងនេះ គឺស្តេចម្នាក់ដែលឈ្មោះរលុបបាត់ បានទិញដើម្បីថ្វាយទៅប្រាសាទទាំងពីរ។

## ២- អត្ថបទដើមជាអក្សរទំនើប

១- ៙ វ្រះកំម្រតេងអញគិរលិង្គតវ្យរិបុន្យវ្រ[ ៈបំ]

២- ន្វសិប្វសគិនក្កស្នាបនាចោងឥតិរិយភូ[[មិ[៥]]]

៣- នុផ្ទេបុជាវ្រះកម្រតេងអញ[៦]គិរលិង្គអំវិ---

៤- ថ្នលិស្រេម្វាយិដេងទៅល្វះហ៊ិ--(ង៊ី)--តោ

៥- យិវ៉ាយវ្យសំទប្បនោះទៅតោយិបគ្និម[ល្វះ]

៦- តគិផ្ទុវ្រេក្កផ្ទុម្វាយិទៅវកោងផ្ទុម្វាយិច្វ

៧- លិវ្នុរិស្រមោតោយិឧត្តរផ្ទុវកោងគោលិថ្មេ[៧]ទៅ

៨- ទក្សិ[[ណា]]ល្វះតគិស្ទុលិគោលិម្វាយិតនោះអំវិ

---

[៤] សូមជ្រើសយកលេខ K.844។

[៥] លោក សេដែស ជួសពាក្យនេះជា ភូ[[មិយ៊ិ]]។

[៦] លោក សេដែស និងចេណ្ណឹរ អានជា «កំម្រតេងអញ»។

[៧] យោងតាមលោក សេដែស, ១៩៥៣, គួរតែជា «ថ្មោ» តែចារក្មេចស្រៈ «ា»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៩- តនោះទៅបុរ្វ[8]ល្វះតគិមុ[9]ត្រវាង៍ស្វាយិធ

១០- ត្តោយិនៃបូតិយិគោលិម្វាយិនោះទៅល្វះតគិ

១១- មុត្រវាង៍ស្វាយិធត្តោយិ[ត៍]គាន[10]សោតិគោល[[ម្វា]]

១២- យិអំរិតនោះទៅឧត្តរសោតិល្វះតិបគ្និមស្តុកិស្វិ-

១៣- គោលិម្វាយ្តិតនោះអំរិតនោះទៅបគ្និមល្វះតគិ

១៤- ត្រវាង៍ធ្នារតីអគ្នេយតិឧត្តរវ្រះកម្រតេង៍អញគិរ[[លិ]]

១៥- ង្គតោយឧត្តរផ្ទុសំទប្បមុត្រវាង៍វ្វាង៍[11]ត[12]ឥគាន[13]គោ[[លិម្វា]]

១៦- យិអំរិតនោះទៅឧត្ត[[រ]]ជេង៍បូនិវាក្តោង្គង្គោល[14][[ម្វាយិ]]

១៧- សំទប្បនោះទៅបគ្និមផ្ទុថ្វាយិលុច្ចស្រេ[[គោលិម្វា]][15]

១៨- យិទៅទក្សិណសំទប្បមុស្ទលា[16]តិវាយវ្យ[[តិបគ្និ]]

១៩- មផ្ទុគោលិម្វាយិនេះ[17]កុមិ[18]តពោះនេះតិស្តេ[[ង៍]]--

២០- ទុញ្ញិបិឱយិតវ្រះកម្រតេង៍អញ្ញិគិរ[[លិង្គ]]

---

[8] លោក សេដែស និង៍ចេណ្ណឹរ អានជា «បូរ្វ៌» តាមប្រកពពាក្យ ប៉ុន្តែតាមរូបរាង៍អក្សរនៅលើថ្ម គឺជា «បុរ្វ៌»។

[9] ពាក្យនេះតាមត្រឹមត្រូវជា «មុំ» ប៉ុន្តែគ្រប់ពាក្យនេះ ចារនៅលើសិលាចារឹកពុំមានស្រៈ «ំ» ទេ។

[10] លោក សេដែស និង៍ចេណ្ណឹរ អានជា «ឦគាន» តាមប្រកពពាក្យ។

[11] យោង៍តាមលោក សេដែស, ១៩៥៣, អំណាននេះត្រឹមត្រូវទៅតាមអត្ថបទចារឹក តែពាក្យនេះប្រហែលជា «វ្វង៍» ឬ «វ្វាង៍»។

[12] លោក ចេណ្ណឹរ អានជា «តិ» ដោយថែមស្រៈ «ិ» ដើម្បីឱ្យឃ្លាមានអត្ថន័យត្រឹមត្រូវ។

[13] លោក សេដែស និង៍ចេណ្ណឹរ អានជា «ឦគាន»។

[14] លោក សេដែស និង៍ចេណ្ណឹរ អានជា «វាក្តោង្គិង្គោល»។

[15] លោក សេដែស ពុំអាន។

[16] លោក សេដែស និង៍ចេណ្ណឹរ អានជា «ស្ទលា»។

[17] លោក សេដែស និង៍ចេណ្ណឹរ អានជា «នោះ»។

[18] លោក សេដែស និង៍និង៍ចេណ្ណឹរ អានជា «ភូមិ»។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង៍

## ៣- អត្ថបទប្រែសម្រួល

(១-២) (ប្រាសាទ)ព្រះគម្តែងអញសិវលិង្គទាំងពីរ (ជា)បុណ្យព្រះបំនួស(ដែល)បួសគឺ(ជា)អ្នកស្ថាបនាសង់(ប្រាសាទ)ឥដ្ឋ។

(២-១៩) វីដីនិងភោគផល(សម្រាប់)បូជាព្រះគម្តែងអញសិវលិង្គ ចាប់ពី---ថ្នល់ស្រែ(ប្រវែង)មួយជើង (ដីនោះ)ទៅរហូតដល់---ទៅដល់(ត្រង់ដី?នា)ទិសពាយព្យក្បែរនោះ។ ទៅលិចរហូតដល់ផ្លូវព្រែក(ត្រង់)ផ្លូវមួយទៅពកោង (និង)ផ្លូវមួយចូល(ទៅ)ផ្ទះស្រម៉។ ទៅជើង(ដល់)ផ្លូវពកោង(ត្រង់)គោលថ្ម។ ទៅត្បូងរហូតដល់ស្នួល(ត្រង់ថ្ម)គោលមួយនៅទីនោះ។ ចាប់ពីត្រង់នោះទៅកើតរហូតដល់ជ្រុងត្រពាំងស្វាយឆត ដល់ទិសនិរតី(ត្រង់ថ្ម)គោលមួយ(នៅទី)នោះ។ ទៅរហូតដល់ជ្រុងត្រពាំងស្វាយឆត ដល់ទិសឦសាន(ត្រង់ថ្ម)គោលមួយដែរ។ ចាប់ពីត្រង់នោះទៅជើងរហូតដល់ខាងលិចស្តុកស្ង៊-(ត្រង់)គោលមួយនៅទីនោះ។ ចាប់ពីត្រង់នោះទៅលិចរហូតដល់ត្រពាំងធ្មារ ទៅទិសអាគ្នេយ៍(ដល់)ខាងជើងព្រះគម្តែងអញសិវលិង្គ ទៅខាងជើងផ្លូវក្បែរជ្រុងត្រពាំងក្ងាំងដល់ទិសឦសាន(ត្រង់ថ្ម)គោលមួយ។ ចាប់ពីត្រង់នោះទៅជើង(មានស្រែប្រវែង)បួនជើង (ទៅដល់?)វាកតោងតង(ត្រង់ថ្ម)គោលមួយនៅក្បែរនោះ។ ទៅខាងលិច (នៅ)ផ្លូវខាងលិចស្រែ(ត្រង់)គោលមួយ។ ទៅត្បូងក្បែរជ្រុងទួលដល់ខាងពាយព្យ (និង)ខាងលិចផ្លូវ(ត្រង់ថ្ម)គោលមួយ។

(១៩-២០) ដីទាំងអស់នេះ ស្តេង--ទិញដើម្បីថ្វាយដល់(ប្រាសាទ)ព្រះគម្តែងអញសិវលិង្គ។

## ៤- «ចោងឥត៑»

ពាក្យ «ចោងឥត៑» នេះ បើបកប្រែពីពាក្យបុរាណសងមកពាក្យទំនើបត្រង់ៗ គឺ «ចងឥដ្ឋ»។ សម្រាប់ពាក្យ «ចង» បច្ចុប្បន្ន មនុស្សម្នាទូទៅ ហាក់នឹកសំដៅដល់ការភ្ជួចភ្ជាប់គ្នាធ្វើជាចំណង គឺចងខ្សែជាដើម។ យើងអាចគិតឆ្ងល់ថា «ចងឥដ្ឋ» ដូចខ្សែម្តេចកើតទៅ? យ៉ាងណាពាក្យ «ចង» នេះ មានន័យលើពីនេះ ហើយន័យសំខាន់បំផុតគឺ ភ្ជាប់គ្នា។ ដូច្នោះ «ចងឥដ្ឋ» គឺភ្ជាប់ឥដ្ឋ ឬរៀបឥដ្ឋ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

បើមើលឱ្យលើសពីនេះ ក្នុងភាសាខ្មែរពីបុរាណមក មានបម្រែបម្រួលមួយគួរឱ្យកត់សម្គាល់នឹងយកមកនិយាយ ដើម្បីពន្យល់អំពីបញ្ហានេះ។ ការប្រែប្រួលនោះ កើតមានរវាងព្យញ្ជនៈ «ច» និង «ស» ដូចជាពីបុរាណប្រើពាក្យ «ច្មិង» ឯបច្ចុប្បន្នក្លាយមកជា «ស្មឹង» ជាដើម។[១៩] បើមើលឃើញត្រង់ចំណុចនេះ គង់នឹងយើងនឹកពាក្យ «ចង់ឥដ្ឋ» មានន័យប្រហាក់ប្រហែលនឹងពាក្យ «សង់ឥដ្ឋ» ជាពុំខាន។ តាមរយៈការពិនិត្យមើលពាក្យ «ចោង» កាលពីបុរាណ ដោយពឹងផ្អែកលើទិន្នន័យសិលាចារឹកភាសាខ្មែរបុរាណនានា យើងសង្កេតឃើញមានប្រើដូចខាងក្រោមនេះ៖

- ចោងប្រាសាទ (៩១, ១៩៤, ២៣៥) = សង់ប្រាសាទ
- ចោងគិលាប្រាសាទ (២៣៥) = សង់ប្រាសាទថ្ម
- ចោងវលភិ (២៣៥) = សង់ប្រាសាទវលភិ
- ចោងកំវេង (២៣៥) = សង់កំពែង
- ចោងឥត (២៣៨, ៣៤១, ៨៤៤) = សង់(ប្រាសាទ)ឥដ្ឋ

នាសម័យបច្ចុប្បន្ន យើងក៏សង្កេតឃើញមានប្រើពាក្យ «ចង» ជាមួយពាក្យក្នុងសំណង់ស្ពាបត្យកម្មដែរ គឺពាក្យ «ចងស្ពាន» ដូចឃ្លាថា «ចងស្ពាន មានមេត្រី»។ ឃ្លានេះអាចឱ្យយើងបកស្រាយថា «ភ្ជាប់ស្ពាន ដើម្បីសាងមេត្រីនឹងគ្នា» ឬថា «សង់ស្ពានដើម្បីឆ្លងទៅរកមេត្រីភាព»។ ដែលកាន់តែច្បាស់នោះ នៅក្នុងការសម្ដែងរបាំរឿងរាមកេរ្តិ៍ មានឈុតមួយត្រង់ហនុមានត្រូវសង់ស្ពានដើម្បីឆ្លងទៅក្រុងលង្កា ខ្មែរយើងនិយមហៅថា «ហនុមានចងស្ពាន» ដែលឯកសារសំណេរខ្លះក៏សរសេរថា «ចងថ្នល់» ឬ «កថ្នល់» ផងដែរ។

## ៥- ស្ថាននាម «វកោង»

បើយើងមើលស្ថាននាមនេះ តាមការវិវត្តភាសាខ្មែរ ពាក្យ «វកោង» ពីបុរាណនឹងក្លាយមកជាពាក្យទំនើបថា «ពកោង»។ មានអ្នកស្រាវជ្រាវមួយចំនួន បានសន្និដ្ឋានថាពាក្យ «វកោង» នៅក្នុងសិលាចារឹកនេះ គឺត្រូវគ្នាឬមានទំនាក់ទំនងនឹងភូមិ «បង្កោង» ដែលស្ថិត

[១៩] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/17515

នៅក្នុងឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។[២០] នៅភូមិបង្កោងនេះ នៅរក្សាកិច្ចទំនៀមពីបុរាណជាច្រើន ប៉ុន្តែអ្វីដែលគេចាប់អារម្មណ៍និងស្គាល់ច្រើនជាងគេ ការចាប់ត្រីរួមគ្នានៅត្រពាំងបឹង ដើម្បីធ្វើនំបញ្ចុកយកទៅជុំគ្នានៅកន្លែងធ្វើបុណ្យឡើងមាឃ គឺដើម្បីប្រគេនព្រះសង្ឃផង និងថ្វាយអ្នកតាមផង។[២១]

យ៉ាងនេះក្តី ក៏មានសេចក្តីសន្និដ្ឋានមួយទៀតថា ស្ថាននាម «វកោង៑» កាលពីបុរាណនេះ ទំនងជាវិវត្តមកជាស្ថាននាមភូមិនិងប្រាសាទ «បាគង» ផងដែរ។[២២] ចំណុចដែលយើងអាចសង្កេតពិនិត្យបានទៅលើបញ្ហានេះ គឺព្យញ្ជនៈ «វ» មានការវិវត្តទៅជាព្យញ្ជនៈបបូរមាត់ដូចជា «ព» និង «ភ» ហើយសូរបបូរមាត់ពីរនេះ ក៏អាចក្លាយទៅជាសូរបបូរមាត់ផ្សេងទៀតដូចជា «ប» និង «ផ» ផងដែរ។ ចំណុចនេះ យើងគង់នឹងឃើញបានថា «វ» ក្នុងពាក្យ «វកោង» អាចក្លាយទៅជា «ប» ឬ «បា» បានដែរ។ ឯ «កោង» អាចនៅរក្សាសូរដដែល ឬក្លាយទៅជា «គង»។ ដូច្នេះហើយ ស្ថាននាម «វកោង៑» ពីបុរាណ ពុំអាចឱ្យយើងជ្រះស្រឡះថាត្រូវនឹងទីតាំងណាមួយពិតប្រាកដនោះទេ។ យ៉ាងនេះក្តី តាមលទ្ធភាពនៃការវិវត្តភាសា បានចង្អុលបង្ហាញទីតាំងពីសំខាន់ៗគឺ «បាគង» និង «បង្កោង» ដែលស្ថិតនៅក្នុងស្រុកប្រាសាទបាគង ខេត្តសៀមរាប៕

អរិយធម៌ខ្មែរ KHMER CIVILIZATION

[២០] សូមអានបន្ថែម៖ https://www.yosothor.org/publications/khmer-renaissance/chapter-two/Sambat-ney-sahakkom.html

[២១] សូមអានបន្ថែម៖ https://www.yosothor.org/publications/khmer-renaissance/chapter-one/nom-banh-chok-tmey.html

[២២] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/4217

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

# ឯកសារពិគ្រោះ


ខៀវ ច័ន្ទ

សម្បត្តិរួមនៃសហគមន៍, https://www.yosothor.org/publications/khmer-renaissance/chapter-two/Sambat-ney-sahakkom.html

ញឹម សុធារិទ្ធ

ឈ្មោះប្រាសាទបាគង, https://ams.com.kh/khmercivilization/detail/4217

សួង សុខវ៉ូ

នំបញ្ចុក, https://www.yosothor.org/publications/khmer-renaissance/chapter-one/nom-banh-chok-tmey.html

Cœdès, G.

1953. Inscription de Kŭk Aṅkằñ (K. 844) in *Inscriptions du Cambodge*, Vol. 5. Paris.

Jenner, P.

Stele of Kŭk Aṅkằñ in *Part xml, № 44*. http://sealang.net/ok/corpus.htm

CISARK

Kôk Angkanh. https://cisark.mcfa.gov.kh/core/showsite.php?id=4844

# បញ្ជីរូបភាព



រូបថតផ្តែរប្រាសាទគោកអង្គាញ់ (ប្រភពរូបៈ EFEO_CAM17493)



រូបថតសសរពេជ្រនិងថ្មទ្រនាប់ជណ្តើរប្រាសាទគោកអង្គាញ់ (ប្រភពរូបៈ EFEO_CAM11201)

អត្ថបទដោយៈ ហ៊ិន ឈុនតេង



រូបថតសិលាចារឹកប្រាសាទគោកអង្គាញ់ (រូបថត៖ EFEO)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណៅផ្ដិតសិលាចារឹកប្រាសាទគោកអង្គាញ់ (រូបថត៖ EFEO_ CAM17065)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង